# កិច្ចតែងការបង្រៀន

ថ្ងៃចន្ទ២រោចខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ត្រូវនឹងថ្ងៃទី១១ខែសីហាឆ្នាំ២០២៥

- មុខវិជ្ជា៖ សិក្សាសង្គម
- ប្រធានបទ៖
- សកម្មភាពគោល៖ ល្បែង
- ចំណងជើងមេរៀន ៖ «តំរៀបធុងសំរាមឱ្យត្រូវតាមពណ៌»
- ថ្នាក់កម្រិត ខ្ពស់
- រយ:ពេល ៣០នាទី

១.វត្ថុបំណង

- វិជ្ជាសម្បទា៖ កុមារប្រាប់បានពីពណ៌ធុងសំរាមនិងដាក់ពណ៌ត្រូវតាមប្រភេទធុងសំរាមនីមួយៗបានត្រឹមត្រូវតាមរយ:ការណែនាំរបស់គ្រូ។
- បំណិនសម្បទា៖ កុមារយល់ពីរបៀបលេង ការចោលសំរាម និងការដាក់ពណ៌ត្រូវតាមប្រភេទធុងសំរាមនីមួយៗបានត្រឹមត្រូវតាមរយ:ការអនុវត្តផ្ទាល់ ។
- ចរិយាសម្បទា៖ បណ្តុះស្មារតី អត់ធ្មត់ តស៊ូក្នុងការលេង។

២.ការរៀបចំ

- សម្ភារ:គ្រូ៖ កូនកាសពណ៌( លឿង ក្រហម ស្វាយ ខៀវ ) ផ្ទាំងរូបធុងសំរាម
- សម្ភារ:សិស្ស៖  កូនកាសពណ៌( លឿង ក្រហម ស្វាយ ខៀវ ) ផ្ទាំងរូបធុងសំរាម
- ការរៀបចំ៖ ( ចែកជា២ក្រុម)ដោយមួយក្រុមមាន គ្នា៤នាក់
- ទីកន្លែង៖  ក្នុងថ្នាក់

៣.ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -រាប់ចំនួនកុមារ<br>-ពិនិត្យក្រចកដៃនិងសម្លៀកបំពាក់<br>-កូនៗអង្គុយឱ្យត្រង់ខ្លួន<br>-នាំកុមារច្រៀងនិងធ្វើកាយវិការ ចម្រៀង «លោកតាអាប្រាហាំ» | ជំហានទី១<br>+លំនឹងថ្នាក់<br>-ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យ<br><br>-៣ផ្ទឹងសណ្តាប់ធ្នាប់<br>-ប្រមូលអារម្មណ៍<br><br>ជំហានទី២<br>+រំឭកមេរៀនចាស់ | -នៅស្ងៀម<br>-ដាក់ជូនគ្រូពិនិត្យ<br><br>-អង្គុយត្រង់ខ្លួនស្តាប់គ្រូ<br>-ច្រៀងនិងធ្វើទាំងអស់គ្នា |

| | | |
|---|---|---|
| -តើថ្ងៃមុនអ្នកគ្រូបានបង្រៀនមេរៀនសិក្សាសង្គមកូនពីអ្វីដែរ? | -ល្បែង៖ «បត់ក្រដាសធ្វើជាកាបូប»<br><br>+ទំនាក់ទំនងមេរៀនថ្មី | -ឆ្លើយ |
| -ពេលកូនៗញ៉ាំនំរួច តើកូនត្រូវយកសំបកនំទៅចោលនៅឯណា? | -ចោលនៅក្នុងសំរាម | -ឆ្លើយ |
| | ជំហានទី៣<br>+មេរៀនថ្មី | |
| -ថ្ងៃនេះអ្នកគ្រូមានល្បែងថ្មីមួយយកមកនាំកូនៗលេង | -ល្បែង៖«តំរៀបធុងសំរាមឱ្យត្រូវតាមពណ៌» | -ស្តាប់ |
| -តស់!កូនអានចំណងជើងមេរៀនតាមអ្នកគ្រូ | -អានចំណងជើង | -អានតាមគ្រូ |
| -បង្ហាញសម្ភារ:ឱ្យកុមារមើល | -បង្ហាញសម្ភារ:<br> | -មើល |
| -តើធុងសំរាមទាំងអស់មានពណ៌អ្វីខ្លះ? | -លឿង ក្រហម បៃតង ស្វាយ ខៀវ | -ឆ្លើយ |
| -ចាស ចឹងកូនកាសក៏មានពណ៌ដូចធុងសំរាមដែរ | -កូនកាស( លឿង ក្រហម បៃតង ស្វាយខៀវ) | -ស្តាប់ |
| -គ្រូណែនាំពីរបៀបលេង<br>+អ្នកគ្រូចែកកូនក្នុងមួយក្រុម៤នាក់ ដោយក្នុងមួយក្រុមមានផ្ទាំងធុងសំរាមចំនួន៤ និងកូនកាស។ បន្ទាប់មកកូនត្រូវយកកូនកាសទៅដាក់រៀបឱ្យត្រូវតាមពណ៌ធុងសំរាម ប្រសិនបើក្រុមណារៀបបានត្រឹមត្រូវនឹងរួចមុនគេ ក្រុមនោះជាអ្នកឈ្នះទី ១ ក្រុមដែលរួចបន្ទាប់ឈ្នះទី ២ ។បញ្ជាក់៖ ពេលរួចគ្រូត្រូវ | -ណែនាំពីរបៀបលេង | -ស្តាប់ |

| | | |
|---|---|---|
| ពិនិត្យឡើងវិញផងខ្លាចពួកគាត់ដាក់ច្រលំពណ៌ ឬចន្លោះ ប្រសិនបើដាក់ចន្លោះ ចាត់ទុកថាចាញ់។ | | |
| -ចឹងកូនៗស្ដាប់បានទេ | | -ឆ្លើយ |
| -ហៅកុមារម្នាក់មកនិយាយពីរបៀបលេងឡើងវិញ | | -ឡើងមកនិយាយ |
| -ចែកសម្ភារៈតាមក្រុម រួចអនុវត្ត | -ចែកសម្ភារៈ | -ទទួល រួចអនុវត្ត |
| -គ្រូដើរសម្របសម្រួល | | -ទទួលយកការណែនាំរបស់គ្រូ |
| | ជំហានទី៤<br>+ពង្រឹងមេរៀន | |
| -សួរចំណងជើងមេរៀនឡើងវិញ | -ល្បែង៖«តំរៀបធុងសំរាមឱ្យត្រូវតាមពណ៌» | -ឆ្លើយ |
| -តើធុងសំរាមដែលអ្នកគ្រូយកមកឱ្យកូនលេងអំបាញ់មិញមានពណ៌អ្វីខ្លះ? | -លឿង ក្រហម បៃតង ស្វាយ ខៀវ | -ឆ្លើយ |
| | ជំហានទី៥<br>+បណ្ដាំផ្ញើ | |
| -កូនពិតជាពូកែៗណាស់ហើយចេះស្ដាប់បង្គាប់អ្នកគ្រូទៀត | -ការលើកសរសើរ | -ស្ដាប់ |
| -ពេលត្រលប់ទៅផ្ទះកុំភ្លេចប្រាប់ប៉ាម៉ាក់កូនផង ថាកូនៗបានលេងល្បែង«តំរៀបធុងសំរាមឱ្យត្រូវតាមពណ៌» | -ផ្ដាំផ្ញើ | -បាទ/ចាស |

ថ្ងៃចន្ទ២រោចខែស្រាពណ៍ ឆ្នាំម្សាញ់សប្តស័ក ព.ស២៥៦៩
ត្រូវនឹងថ្ងៃទី១១ខែសីហា ឆ្នាំ២០២៥
គ្រូបន្ទុកថ្នាក់

មាន សុផា

បានឃើញនិងឯកភាព
នាយិកាសាលា

អ៊ុំ ណារឿន